# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ
## KINGDOM OF CAMBODIA
Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ៦២៧ MOC / SM 2008

# ប្រ កា ស

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៩អនក្រ.បក ចុះថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) ឱ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) ចំណុះក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់ក្រសួង

## <u>ស ម្រេ ច</u>

**<u>ប្រការ១</u> : នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ** ស្ថិតនៅក្រោមការគ្រប់គ្រង និងដឹកនាំផ្ទាល់របស់អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ នីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូល ) មានតួនាទី និងភារកិច្ចដូចតទៅ ៖-

- សិក្សា និងណែនាំមតិ លើទិដ្ឋភាពបច្ចេកទេសផ្នែកគុណភាព សុវត្ថិភាព នៃផលិតផល
- ព្រាងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផល
- រួមផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេតទូទាំងប្រទេស
- ទំនាក់ទំនងជាមួយស្ថាប័នស្តង់ដារ ស្ថាប័នត្រួតពិនិត្យផ្សេងៗ និងអ្នកមានមុខរបរពាក់ព័ន្ធ
- រួមកសាងកម្រងព័ត៌មាន នៃគ្រោះសម្រាប់កិច្ចការវាយតម្លៃគ្រោះ នៃផលិតផល
- ទទួលផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តនីតិវិធានការអនាម័យ និងភូតគាមអនាម័យ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៨ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

- សម្របសម្រួល សហការ ប្រមូលផ្តុំព័ត៌មាន ជាមួយគណៈកម្មាធិការកូដិច (Codex)ជាតិ និងស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ចម្លើយ ជូនលេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងអង្គការពាក់ព័ន្ធដទៃទៀត
- ស្រាវជ្រាវពីវិធានការ ផ្នែកវិធានការអនាម័យ និងភូតគាមអនាម័យជាក់លាក់ ដែលមានប្រយោជន៍ដល់ការនាំចេញរបស់កម្ពុជា
- ផ្តល់គំនិតជូនលេខាធិការដ្ឋានគណៈកម្មាធិការកូដិច (Codex)ជាតិ អំពីផលប៉ះពាល់ដល់កម្ពុជា នៃបណ្តាការងារកសាងស្តង់ដារម្ហូបអាហារ បញ្ហាត្រួតពិនិត្យម្ហូបអាហារ និងបញ្ហាភូតគាមអនាម័យ
- ធ្វើការផ្សព្វផ្សាយអនុវត្ត ក្នុងប្រទេសនូវ ព័ត៌មាន អំពីបណ្តាវិធានការទាក់ទងនឹងអនាម័យ និងភូតគាមអនាម័យ
- ជំនួយការងារផ្នែកលេខាធិការ និងរដ្ឋបាល សម្រាប់លេខាធិការដ្ឋានគណៈកម្មាធិការកូដិច(Codex)ជាតិ
- ប្រមូលផ្តុំគ្រប់គ្រងរក្សាឯកសារវិទ្យាសាស្ត្របច្ចេកទេស ស្តង់ដារ និងបញ្ញត្តិបច្ចេកទេស
- ទទួលបន្ទុកនូវដំណើរការ និងបច្ចុប្បន្នភាព នៃគេហទំព័ររបស់អគ្គនាយកដ្ឋាន
- ទទួលបន្ទុកបន្ថែមនូវដំណើរការ និងបច្ចុប្បន្នភាព នៃគេហទំព័ររបស់នាយកដ្ឋាន
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មានពីសុវត្ថិភាពផលិតផលម្ហូបអាហារសម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀតទៅតាមការជាក់ស្តែង
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មានផលិតផលប្រើប្រាស់ (ក្រៅពីម្ហូបអាហារ) មិនប្រកបដោយសុវត្ថិភាពសម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀតទៅតាមការជាក់ស្តែង
- រៀបចំ គោលនយោបាយជាតិ អំពីបញ្ហាគុណភាព និងសុវត្ថិភាពនៃផលិតផល និងសេវា
- កំណត់វិធីសាស្ត្រត្រួតពិនិត្យ
- ផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើការអង្កេត ផ្នែកគុណភាព សុវត្ថិភាព
- ស្រាវជ្រាវ ពីអនាម័យ និងអតិសុខុមជីវសាស្ត្រពាក់ព័ន្ធនឹងម្ហូបអាហារ
- ស្រាវជ្រាវ បញ្ហាអនាម័យកែច្នៃផលិតផលម្ហូបអាហារ
- ស្រាវជ្រាវ បញ្ហាសារធាតុបន្ថែមលើម្ហូបអាហារ ផលិតផលប៉ះផ្ទាល់នឹងម្ហូបអាហារ ផលិតផលសម្រាប់លាងសំអាត
- ស្រាវជ្រាវ បញ្ហាអាហារូបត្ថម្ភ
- ស្រាវជ្រាវ បញ្ហាពាក់ព័ន្ធសារធាតុគីមី និងផលិតផលមិនមែនម្ហូបអាហារ គ្រប់គ្រងដោយបញ្ញត្តិបច្ចេកទេស
- ទំនាក់ទំនងជាមួយ អង្គការអន្តរជាតិ និងស្ថាប័នត្រួតពិនិត្យនៃប្រទេសនានា
- សម្របសម្រួលជំនួយបច្ចេកទេស
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំប្រគល់ជូន ។

**ប្រការ២** : នាយកដ្ឋានបច្ចេកទេស និងទំនាក់ទំនងសាធារណៈ មាន ការិយាល័យចំណុះចំនួន ៤ ៖-

១-ការិយាល័យបច្ចេកទេសផលិតផលម្ហូបអាហារ

២-ការិយាល័យបច្ចេកទេសផលិតផលមិនមែនម្ហូបអាហារ

៣-ការិយាល័យទំនាក់ទំនងព័ត៌មានសុវត្ថិភាពផលិតផល

៤-ការិយាល័យផ្តល់ចម្លើយការអនុវត្តន៏វិធានអនាម័យ និងភូតគាមអនាម័យ



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៨២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

**ប្រការ៣: ការិយាល័យបច្ចេកទេសផលិតផលម្ហូបអាហារ** ទទួលបន្ទុក:

- សិក្សា និងណែនាំមតិ លើទិដ្ឋភាពបច្ចេកទេសផ្នែកគុណភាព សុវត្ថិភាព នៃផលិតផលម្ហូបអាហារ
- ព្រាងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផលម្ហូបអាហារ
- រួមផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេតផលិតផលម្ហូបអាហារទូទាំងប្រទេស
- ទំនាក់ទំនងជាមួយស្ថាប័នស្តង់ដារ ស្ថាប័នត្រួតពិនិត្យផ្សេង និងអ្នកមានមុខរបរពាក់ព័ន្ធ
- រៀបចំគោលនយោបាយជាតិ អំពីគុណភាព និងសុវត្ថិភាព នៃផលិតផល និងសេវា
- កំណត់វិធីសាស្ត្រត្រួតពិនិត្យផលិតផលម្ហូបអាហារ
- ផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើការអង្កេត ផ្នែកគុណភាព សុវត្ថិភាព
- ស្រាវជ្រាវ ពីអនាម័យ និងអតិសុខុមជីវសាស្ត្រពាក់ព័ន្ធនឹងម្ហូបអាហារ
- ស្រាវជ្រាវ បញ្ហាអនាម័យកែច្នៃផលិតផលម្ហូបអាហារ
- ស្រាវជ្រាវ បញ្ហាសារធាតុបន្ថែមលើម្ហូបអាហារ ផលិតផលប៉ះផ្ទាល់នឹងម្ហូបអាហារ ផលិតផលសម្រាប់លាងសម្អាត
- កសាងកម្រងព័ត៌មាន នៃគ្រោះសម្រាប់កិច្ចការវាយតម្លៃគ្រោះ នៃផលិតផលម្ហូបអាហារ
- ស្រាវជ្រាវបញ្ហាភាពបង្កគ្រោះសារធាតុគីមីចម្លង ក្នុងផលិតផលម្ហូបអាហារ
- ស្រាវជ្រាវបញ្ហាអាហារូបត្ថម្ភ
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៤: ការិយាល័យបច្ចេកទេសផលិតផលមិនមែនម្ហូបអាហារ** ទទួលបន្ទុក :

- សិក្សា និងណែនាំមតិ លើទិដ្ឋភាពបច្ចេកទេសផ្នែកគុណភាព សុវត្ថិភាព នៃផលិតផលមិនមែនម្ហូបអាហារ
- ព្រាងបទប្បញ្ញត្តិបច្ចេកទេសពាក់ព័ន្ធនឹងគុណភាព សុវត្ថិភាពផលិតផលមិនមែនម្ហូបអាហារ
- រួមផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេតផលិតផលមិនមែនម្ហូបអាហារទូទាំងប្រទេស
- កសាងកម្រងព័ត៌មាននៃគ្រោះ សម្រាប់កិច្ចការវាយតម្លៃគ្រោះ នៃផលិតផល មិនមែនម្ហូបអាហារ
- ទំនាក់ទំនងជាមួយស្ថាប័នស្តង់ដារ ស្ថាប័នត្រួតពិនិត្យផ្សេង ៗ និងអ្នកមានមុខរបរពាក់ព័ន្ធ
- រៀបចំ គោលនយោបាយជាតិ អំពីបញ្ហាគុណភាព និងសុវត្ថិភាពនៃផលិតផល និងសេវា
- កំណត់វិធីសាស្ត្រត្រួតពិនិត្យផលិតផលមិនមែនម្ហូបអាហារ
- ផ្តល់មតិបច្ចេកទេស លើកម្មវិធីធ្វើអង្កេត ផ្នែកគុណភាព សុវត្ថិភាពផលិតផលមិនមែនម្ហូបអាហារ
- ស្រាវជ្រាវ បញ្ហាពាក់ព័ន្ធសារធាតុគីមី និងផលិតផលមិនមែនម្ហូបអាហារ គ្រប់គ្រងដោយបញ្ញត្តិបច្ចេកទេស
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៥: ការិយាល័យទំនាក់ទំនងព័ត៌មានសុវត្ថិភាពផលិតផល** ទទួលបន្ទុក:

- ទទួលបន្ទុកបន្ថែមនូវដំណើរការ និងបច្ចុប្បន្នភាព នៃគេហទំព័ររបស់នាយកដ្ឋាន
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មានពីសុវត្ថិភាពផលិតផលម្ហូបអាហារសម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀតទៅតាមការជាក់ស្តែង
- ទទួលបន្ទុកជាចំណុចទំនាក់ទំនងថ្នាក់ជាតិ នៃប្រព័ន្ធបញ្ជូនព័ត៌មានលើផលិតផលប្រើប្រាស់ (ក្រៅពីម្ហូប



ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៨៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៨៨ / ៥៥១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com

អាហារ ) មិនប្រកបដោយសុវត្ថិភាព សម្រាប់តំបន់អាស៊ាន និងតំបន់ផ្សេងទៀតទៅតាមការជាក់ស្តែង
- ប្រមូលទិន្នន័យព័ត៌មាន នៃគ្រោះផលិតផលសម្រាប់ការផ្សព្វផ្សាយ
- សម្របសម្រួលជំនួយបច្ចេកទេស
- សម្របសម្រួលការរៀបចំផែនការសកម្មភាពនាយកដ្ឋាន
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៦: ការិយាល័យផ្តល់ចម្លើយការអនុវត្តនីតិវិធានអនាម័យ និងភូតគាមអនាម័យ** ទទួលបន្ទុកៈ
- ទទួលផ្តល់ព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តនីតិវិធានអនាម័យ និងភូតគាមអនាម័យក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ
- សម្របសម្រួលសហការណ៍ប្រមូលផ្តុំព័ត៌មានជាមួយគណៈកម្មាធិការកូដិច(Codex)ជាតិ និងស្ថាប័នពាក់ព័ន្ធក្នុងការផ្តល់ចម្លើយជូនលេខាធិការដ្ឋានអាស៊ាន លេខាធិការដ្ឋានអង្គការពាណិជ្ជកម្មពិភពលោក ព្រមទាំងអង្គការពាក់ព័ន្ធដទៃទៀត
- ស្រាវជ្រាវពីវិធានការអនាម័យ និងភូតគាមអនាម័យជាក់លាក់ ដែលមានប្រយោជន៍ដល់ការនាំចេញរបស់កម្ពុជា
- ផ្តល់គំនិតជូនលេខាធិការដ្ឋានគណៈកម្មាធិការកូដិច (Codex)ជាតិ អំពីផលប៉ះពាល់ដល់កម្ពុជា នៃបណ្តាការងារកសាងស្តង់ដារម្ហូបអាហារ បញ្ហាត្រួតពិនិត្យម្ហូបអាហារ និងបញ្ហាភូតគាមអនាម័យ
- ធ្វើការផ្សព្វផ្សាយអនុវត្តក្នុងប្រទេសនូវព័ត៌មានអំពីបណ្តាវិធានការទាក់ទងនឹងអនាម័យនិងភូតគាមអនាម័យ
- ជំនួយការផ្នែកលេខាធិការ និងរដ្ឋបាលសម្រាប់ លេខាធិការដ្ឋានគណៈកម្មាធិការកូដិច (Codex) ជាតិ
- ប្រមូលផ្តុំគ្រប់គ្រងរក្សាឯកសារវិទ្យាសាស្ត្របច្ចេកទេស ស្តង់ដារ និងបញ្ញត្តិបច្ចេកទេស
- អនុវត្តភារកិច្ចពាក់ព័ន្ធផ្សេងៗទៀតដែលថ្នាក់ដឹកនាំនាយកដ្ឋានប្រគល់ជូន ។

**ប្រការ៧:** នាយិកាខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានគ្រប់អង្គភាពចំណុះក្រសួង ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ២០០៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**កន្លែងទទួល :**

-ដូចប្រការ៧

-ឯកសារ-កាលប្បវត្តិ

2008-08-19 Camcontrol Technic&Relation/CCDG/KSV/KSIT/SSK

ក្រសួងពាណិជ្ជកម្ម
២០ A & B មហាវិថីព្រះនរោត្តម
ភ្នំពេញ ១២២០៥
ព្រះរាជាណាចក្រកម្ពុជា

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៤២៧ ៣៥៨ / ២១៤ ៩៤៦
ទូរសារលេខ: (៨៥៥) ២៣-២១៣-២៤៨ / ៩៩១-៧០៨
អ៊ីម៉ែល : moccabdir@yahoo.com